**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានីភ្នំពេញ**

គណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ

លេខ ១៧៨ គល

# សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

**ការងារសាងសង់អគារសិក្សា០១ខ្នង ស្ថិតក្នុងបរិវេណសាលាបឋមសិក្សាវត្តសន្សំកុសល សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ,**
**សាងសង់អគារសិក្សា០១ខ្នងមាន ស្ថិតក្នុងបរិវេណសាលាបឋមសិក្សាស្ពានថ្ម សង្កាត់ស្ពានថ្ម ខណ្ឌដង្កោ**
**និងសាងសង់អគារមជ្ឈមណ្ឌលចរាចរណ៍ ០១ខ្នង ស្ថិតនៅផ្លូវលេខ៣៣៥**
**សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៨**

រដ្ឋបាលរាជធានីភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក ( គិតទាំងសហគ្រាសឯកត្តបុគ្គល ) និងក្រុមហ៊ុនបរទេស ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា រដ្ឋបាលរាជធានីភ្នំពេញ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារសាងសង់អគារសិក្សា ០១ខ្នង មាន ១០បន្ទប់ ជាន់ផ្ទាល់ដី ជាន់ទី១ ធ្វើអំពីបេតុងអាម៉េ ដំបូលប្រក់ក្បឿង ទំហំ ៤០.៦៥ម x ១០ម ស្ថិតក្នុងបរិវេណសាលាបឋមសិក្សាវត្តសន្សំកុសល សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ, សាងសង់អគារសិក្សា ០១ខ្នងមាន ១០បន្ទប់ ជាន់ផ្ទាល់ដី ជាន់ទី១ ធ្វើអំពីបេតុងអាម៉េ ដំបូលប្រក់ក្បឿង ទំហំ ៤០.៦៥ម x ១០ម ស្ថិតក្នុងបរិវេណសាលាបឋមសិក្សាស្ពានថ្ម សង្កាត់ស្ពានថ្ម ខណ្ឌដង្កោ និងសាងសង់អគារមជ្ឈមណ្ឌលចរាចរណ៍ ០១ខ្នង កំពស់ ៤ជាន់ ធ្វើអំពីបេតុងអាម៉េ មានជាន់ផ្ទាល់ដី ជាន់ទី១ ជាន់ទី២ ជាន់ទី៣ និងដំបូលទែរ៉ាស់ ទំហំ ១៤.៦៥ម x ១៥.៧៥ម ស្ថិតនៅផ្លូវលេខ ៣៣៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៨ ។

រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានអាសយដ្ឋានលេខ៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខ ០៨៧ ៧៥៥ ០០៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ០៨:៣០ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៨:៣០ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ព្រហ ១រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៨

**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងជា**

**ប្រធានគណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ**

**ឃួង ស្រេង**

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ